| ២០៤- លោកស្រី | **ស្រី ច័ន្ទសុជាតា** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកជាវរមន្ត្រី ថ្នាក់លេខ ៤ |
| ២០៥- លោកស្រី | **ខេន ស៊ីទូន** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកជាវរមន្ត្រី ថ្នាក់លេខ ៤ |
| ២០៦- លោក | **ហុង យឿន** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកជាវរមន្ត្រី ថ្នាក់លេខ ៤ |
| ២០៧- លោក | **ឈួន ច័ន្ទតារា** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកជាវរមន្ត្រី ថ្នាក់លេខ ៤ |
| ២០៨- លោក | **តាង ចមទីរះ** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកជាវរមន្ត្រី ថ្នាក់លេខ ៤ |
| ២០៩- លោក | **តូច វ៉ាន់រ៉ា** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកជាវរមន្ត្រី ថ្នាក់លេខ ៤ |
| ២១០- លោកស្រី | **ស្រ៊ុន សុនីតា** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកជាវរមន្ត្រី ថ្នាក់លេខ ៤ |
| ២១១- លោក | **ដាង ប៊ុនថេង** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកជាវរមន្ត្រី ថ្នាក់លេខ ៤ |
| ២១២- លោក | **អ៊ុត សិលា** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកជាវរមន្ត្រី ថ្នាក់លេខ ៤ |
| ២១៣- លោក | **ស្រ៊ឹម កែវឡាយ** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកជាវរមន្ត្រី ថ្នាក់លេខ ៤ |

២១៤- លោក **ផាន សុវណ្ណារា** ពីអនុមន្ត្រី ថ្នាក់លេខ ១ មកជាវរមន្ត្រី ថ្នាក់លេខ ៤

២១៥- លោកស្រី **ជា សុជាតិ** ពីអនុមន្ត្រី ថ្នាក់លេខ ១ មកជាវរមន្ត្រី ថ្នាក់លេខ ៤។

**មាត្រា២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអធិការកិច្ច រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ១កើត ខែ ពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៣៣៧ អនក្រ.ភត

**អនុក្រឹត្យ**

**ស្តីពី**

**ការផ្ទេរភារកិច្ចនិងតែងតាំងមន្ត្រីរាជការ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ១១៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១ .—**

ត្រូវបានផ្ទេរភារកិច្ចមន្ត្រីរាជការចំនួន ៤រូប នៅខេត្តតាកែវ ដូចមានរាយនាមខាងក្រោម៖

១- លោក **ភខ អារុណាន់** ឋានន្តរសក្តិឧត្តមមន្ត្រី ថ្នាក់លេខ៤ ពីអភិបាលនៃគណៈអភិបាលក្រុងដូនកែវ ឱ្យកាន់មុខតំណែងជាអភិបាលនៃគណៈអភិបាលស្រុកអង្គបុរី

២- លោក **ឌឹម គឹមសាន** ឋានន្តរសក្តិឧត្តមមន្ត្រី ថ្នាក់លេខ៦ ពីអភិបាលនៃគណៈអភិបាលស្រុកព្រៃកប្បាស ឱ្យកាន់មុខតំណែងជាអភិបាលនៃគណៈអភិបាលក្រុងដូនកែវ

៣- លោក **គិន តក្កី** ឋានន្តរសក្តិឧត្តមមន្ត្រី ថ្នាក់លេខ៦ ពីអភិបាលនៃគណៈអភិបាលស្រុកកោះអណ្តែត ឱ្យកាន់មុខតំណែងជាអភិបាលនៃគណៈអភិបាលស្រុកព្រៃកប្បាស

៤- លោក **ត្នួន ឈឹម** ឋានន្តរសក្តិឧត្តមមន្ត្រី ថ្នាក់លេខ៦ ពីអភិបាលនៃគណៈអភិបាលស្រុកបាទី ឱ្យកាន់មុខតំណែងជាអភិបាលនៃគណៈអភិបាលស្រុកកោះអណ្តែត។

**មាត្រា២ .—**

ត្រូវបានតែងតាំងលោក **សាយ ចណ្ណា** ឋានន្តរសក្តិវរមន្ត្រី ថ្នាក់លេខ១ ឱ្យកាន់មុខតំណែងជាអភិបាលនៃគណៈអភិបាលស្រុកបាទី ខេត្តតាកែវ។

**មាត្រា៣ .—**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤ .—**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១កើត ខែពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ៣៣៨ អនក្រ.តត

**អនុក្រឹត្យ**
**ស្តីពី**
**ការតែងតាំងមន្ត្រីរាជការ**
**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៣/២១៨៣ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការកែសម្រួលមាត្រា២ និងមាត្រា១៨ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ



95

## សម្រេច

**មាត្រា១ .-**

ត្រូវបានតែងតាំងលោកស្រី **ឌី សុជាតិ** ឋានន្តរសក្តិ វរមន្ត្រី ថ្នាក់លេខ ២ ជាអនុប្រធានអង្គភាពគ្រប់គ្រង និងគាំទ្រកម្មវិធី នៅក្នុងរចនាសម្ព័ន្ធលេខាធិការដ្ឋាន ចំណុះគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)។

**មាត្រា២ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១កើត ខែពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែមេសា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ៤៦ សសរ

**សេចក្តីសម្រេច**
**ស្តីពី**
**ការចាត់តាំងបន្ថែមអនុប្រធាន**
**ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកំពត**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ២១៤ សសរ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពីការចាត់តាំងសមាសភាពក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកំពត
- យោងកម្មវិធីនយោបាយនិងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលសម្រាប់នីតិកាលទី៧ នៃរដ្ឋសភា
- បានឃើញសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលលេខ០៤ សណន ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពីតួនាទី ភារកិច្ច និងរបៀបរបបការងាររបស់ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន
- យោងតាមសំណូមពរចាំបាច់នៃការងារ



ទ

## សម្រេច

**ប្រការ១ .–**

ត្រូវបានចាត់តាំង ឯកឧត្តម **ថេង ច័ន្ទសង្វារ** រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាអនុប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកំពត។

**ប្រការ២ .–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងរដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកំពត អភិបាលនៃគណៈអភិបាលខេត្តកំពត និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១រោច ខែ ចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣ ខែ មេសា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមហាផ្ទៃ** **ក្រសួងសុខាភិបាល**

ទីស្តីការគណៈរដ្ឋមន្ត្រី
ចូល
លេខ 23.09
ថ្ងៃទី 11 ខែ 05 ឆ្នាំ 26
ម៉ោង 9H 17

**លេខ** : ៤៣៧៧.ស.ប្រក

# ប្រកាសអន្តរក្រសួង
## ស្តីពី
## ការជូនដំណឹងអំពីកំណើតរស់ និងមរណភាពទៅមន្ត្រីអត្រានុកូលដ្ឋាន

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃ២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើក្រមរដ្ឋប្បវេណី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១១/០០៧ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧២៣/០០៩ ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ២៣៩ អនក្រ.បក ចុះថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០២៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងមហាផ្ទៃ និងក្រសួងសុខាភិបាល

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

### ប្រការ១ .-

ប្រកាសអន្តរក្រសួងនេះកំណត់អំពីទម្រង់ បែបបទ និងនីតិវិធីនៃការជូនដំណឹងអំពីកំណើតរស់ និងមរណភាព និងនីតិវិធីនៃការបញ្ជូនព័ត៌មានអំពីមូលហេតុនៃមរណភាព ព្រមទាំងនីតិវិធីនៃការកំណត់មូលហេតុនៃមរណភាពដោយការសាកសួរផ្ទាល់មាត់ ដើម្បីធានាថាបុគ្គលគ្រប់រូបដែលកើត និងស្លាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវបានកំណត់អត្តសញ្ញាណ និងចុះបញ្ជី ស្របតាមច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម។

### ប្រការ២ .-

ប្រកាសអន្តរក្រសួងនេះ មានវិសាលភាពអនុវត្តចំពោះរាល់ព្រឹត្តិការណ៍កំណើតរស់ និងមរណភាព ដែលកើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

### ប្រការ៣ .-

វាក្យសព្ទសំខាន់ៗដែលប្រើនៅក្នុងប្រកាសអន្តរក្រសួងនេះ ត្រូវកំណត់និយមន័យដូចខាងក្រោម៖

- **សន្ធានកម្មនៃកម្មវិធីកុំព្យូទ័រ** (Application Programming Interface (API)) សំដៅដល់ច្រកចេញចូលស្តង់ដាដែលអនុញ្ញាតឱ្យទិន្នន័យអាចផ្លាស់ប្តូរពីប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានមួយ ទៅប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានមួយផ្សេងទៀត។ ការផ្លាស់ប្តូរទិន្នន័យគឺតម្រូវឱ្យស្របតាមលក្ខខណ្ឌដែលបានកំណត់។
- **មូលដ្ឋានសុខាភិបាល** សំដៅដល់មូលដ្ឋានសុខាភិបាលសាធារណៈ និងមូលដ្ឋានសុខាភិបាលឯកជន។
- **មូលដ្ឋានសុខាភិបាលសាធារណៈ** សំដៅដល់មន្ទីរពេទ្យជាតិ រួមទាំងមន្ទីរពេទ្យយោធា មន្ទីរពេទ្យនគរបាល និងមន្ទីរពេទ្យបង្អែករាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មណ្ឌលសុខភាព និងប៉ុស្តិ៍សុខភាព។
- **មូលដ្ឋានសុខាភិបាលឯកជន** សំដៅដល់មន្ទីរពេទ្យឯកជន មន្ទីរពហុព្យាបាល មន្ទីរសម្រាកព្យាបាល មន្ទីរសម្ភព-រោគស្ត្រី និងគ្លីនិកឯកជន។
- **ការចាត់ថ្នាក់ជំងឺជាលក្ខណៈអន្តរជាតិ** (International Classification of Diseases (ICD)) សំដៅដល់ស្តង់ដាសកលដែលមានលេខកូដតាមអក្សរឡាតាំង សម្រាប់ជំងឺទាំងអស់ ការរងរបួស និងលក្ខខណ្ឌពាក់ព័ន្ធជំងឺផ្សេងទៀត។ ស្តង់ដានៃការចាត់ថ្នាក់ជំងឺជាលក្ខណៈអន្តរជាតិ អាចត្រូវបានប្រើដើម្បីសរសេរ ឬដាក់កូដជំងឺចេញពីមូលដ្ឋានសុខាភិបាល ឬទិន្នន័យពីលិខិតវេជ្ជសាស្ត្របញ្ជាក់

អំពីមូលហេតុនៃមរណភាព ហើយវាអនុញ្ញាតឱ្យមានការប្រៀបធៀបរវាងមូលដ្ឋានសុខាភិបាល ថ្នាក់ឃុំ/សង្កាត់ ក្រុង/ស្រុក/ខណ្ឌ ថ្នាក់រាជធានី/ខេត្ត ថ្នាក់ជាតិ ឬថ្នាក់អន្តរជាតិ ព្រមទាំងសម្រាប់ការធៀបក្នុងពេលវេលាខុសៗគ្នា។

- **លិខិតបញ្ជាក់វេជ្ជសាស្ត្រអំពីមូលហេតុនៃមរណភាព** សំដៅដល់ទម្រង់ដែលត្រូវបានបំពេញដោយអ្នកជំនាញផ្នែកវេជ្ជសាស្ត្រដែលច្បាប់បានកំណត់ ដើម្បីធ្វើការកត់ត្រា និងបញ្ជាក់អំពីមូលហេតុ និងប្រភេទ ឬរបៀបនៃមរណភាព យោងតាមការចាត់ថ្នាក់ជំងឺជាលក្ខណៈអន្តរជាតិ។
- **មូលហេតុនៃមរណភាព** សំដៅដល់រាល់ជំងឺ លក្ខខណ្ឌនៃការមានជំងឺ ឬរបួសស្នាមដែលបណ្តាលឱ្យ ឬរួមចំណែកឱ្យមរណភាពមួយកើតឡើង និងកាលៈទេសៈនៃគ្រោះថ្នាក់ ឬអំពើហិង្សាដែលបង្កឱ្យមានរបួសស្នាមទាំងនោះ។ និយមន័យនេះមានគោលបំណងធានាថារាល់ព័ត៌មានពាក់ព័ន្ធត្រូវបានកត់ត្រា និងធានាថាអ្នកផ្តល់ការបញ្ជាក់មូលហេតុនៃមរណភាព មិនជ្រើសរើសយកតែលក្ខខណ្ឌមួយចំនួនសម្រាប់កត់ត្រាបញ្ចូល និងប្រានចោលលក្ខខណ្ឌដទៃទៀត។
- **មូលហេតុឫសគល់នៃមរណភាព** (UCOD) សំដៅដល់ជំងឺ ឬរបួសស្នាមដែលបានផ្តួចផ្តើមឱ្យកើតមាននូវព្រឹត្តិការណ៍មួយចំនួន ដោយព្រឹត្តិការណ៍ទាំងនោះបណ្តាលឱ្យមរណភាពមួយកើតឡើងផ្ទាល់ ឬកាលៈទេសៈនៃគ្រោះថ្នាក់ ឬអំពើហិង្សាដែលបានបង្កឱ្យមានរបួសស្នាមរហូតដល់ស្លាប់។
- **មូលហេតុឫសគល់ដើមនៃមរណភាព** (FUCOD) សំដៅដល់មូលហេតុដែលត្រូវបានជ្រើសរើសក្រោយការដាក់កូដប្រើប្រាស់ការចាត់ថ្នាក់ជំងឺជាលក្ខណៈអន្តរជាតិ។

## ជំពូកទី២
## ទម្រង់ និងព័ត៌មាននៃលិខិតជូនដំណឹងអំពីកំណើតរស់ និងមរណភាព

**ប្រការ៤ .-**

ព័ត៌មានដែលចាំបាច់នៃលិខិតជូនដំណឹងអំពីកំណើតរស់ ត្រូវបានប្រើប្រាស់សម្រាប់ជូនដំណឹងអំពីកំណើតរស់ដែលកើតឡើងនៅក្នុងមូលដ្ឋានសុខាភិបាល ឬនៅក្រៅមូលដ្ឋានសុខាភិបាល រួមមាន៖

- ប្រភេទមូលដ្ឋានសុខាភិបាល
- ប្រភេទទីកន្លែងកំណើត
- លេខកូដមូលដ្ឋានសុខាភិបាល
- ឈ្មោះទារក (បើមាន)
- ភេទទារក
- ទម្ងន់ទារកកើត
- ប្រភេទកំណើតទារក
- ថ្ងៃខែឆ្នាំ និងពេលវេលានៃកំណើត
- ទីកន្លែងកំណើត
- ប្រភេទអ្នកផ្តល់សេវាសម្រាលកូន
- ឈ្មោះ និងលេខទូរសព្ទរបស់ម្តាយ
- លំនៅឋានបច្ចុប្បន្នរបស់ម្តាយ
- ឈ្មោះ និងលេខទូរសព្ទរបស់ឪពុក។

លិខិតជូនដំណឹងអំពីកំណើតរស់ មានទម្រង់ជាក្រដាស និង/ឬអេឡិចត្រូនិក។

ទម្រង់ នៃលិខិតជូនដំណឹងអំពីកំណើតរស់ ជាក្រដាស ជាឧបសម្ព័ន្ធទី១ នៃប្រកាសអន្តរក្រសួងនេះ។

**ប្រការ៥ .-**

ព័ត៌មានដែលចាំបាច់នៃលិខិតជូនដំណឹងអំពីមរណភាព ត្រូវបានប្រើប្រាស់សម្រាប់ជូនដំណឹងអំពីមរណភាព ដែលកើតឡើងនៅក្នុងមូលដ្ឋានសុខាភិបាល ឬនៅក្រៅមូលដ្ឋានសុខាភិបាល រួមមាន៖

- ប្រភេទមូលដ្ឋានសុខាភិបាល
- ប្រភេទទីកន្លែងមរណភាព
- លេខកូដមូលដ្ឋានសុខាភិបាល
- ឈ្មោះមរណជន (ប្រសិនបើអ្នកស្លាប់ទើបនឹងកើត ដោយគ្មានឈ្មោះ ចូរសរសេរ "កូនរបស់ឈ្មោះម្ដាយ")
- កាលបរិច្ឆេទ និងពេលវេលានៃមរណភាព
- ថ្ងៃខែឆ្នាំកំណើតរបស់មរណជន (អាយុ បើមិនមានថ្ងៃខែឆ្នាំកំណើត)
- ភេទមរណជន
- ប្រភេទនៃមរណភាព
- លំនៅឋានបច្ចុប្បន្នរបស់មរណជន (ឬលំនៅឋានបច្ចុប្បន្នរបស់ម្ដាយបើមរណជនជាទារក)។

លិខិតជូនដំណឹងអំពីមរណភាព មានទម្រង់ជាក្រដាស និង/ឬអេឡិចត្រូនិក។

ទម្រង់ នៃលិខិតជូនដំណឹងអំពីមរណភាពដែលកើតឡើងនៅក្នុងមូលដ្ឋានសុខាភិបាល ជាក្រដាស ជាឧបសម្ព័ន្ធទី២ នៃប្រកាសអន្តរក្រសួងនេះ។

ទម្រង់ នៃលិខិតជូនដំណឹងអំពីមរណភាពដែលកើតឡើងនៅក្រៅមូលដ្ឋានសុខាភិបាល ជាក្រដាស ជាឧបសម្ព័ន្ធទី៣ នៃប្រកាសអន្តរក្រសួងនេះ។

## ជំពូកទី៣
## បែបបទ និងនីតិវិធីនៃការជូនដំណឹងអំពីកំណើតរស់

**ប្រការ៦ .-**

ដំណើរការចេញ និងបញ្ជូនលិខិតជូនដំណឹងអំពីកំណើតរស់នៅក្នុងមូលដ្ឋានសុខាភិបាលត្រូវបានកំណត់ដូចខាងក្រោម៖

១- ក្នុងករណីកំណើតរស់កើតនៅក្នុងមូលដ្ឋានសុខាភិបាល ឬកើតនៅក្រៅមូលដ្ឋានសុខាភិបាល ហើយម្ដាយ និងទារកធ្វើដំណើរបានទៅដល់មូលដ្ឋានសុខាភិបាលក្នុងរយៈពេល ៤៨(សែសិបប្រាំបី)ម៉ោង បន្ទាប់ពីការសម្រាលទារក និងមុនពេលអនុញ្ញាតឱ្យទារក និង/ឬម្ដាយចាកចេញពីមូលដ្ឋានសុខាភិបាល ប្រធានមូលដ្ឋានសុខាភិបាល ឬបុគ្គលដែលត្រូវបានប្រគល់ភារកិច្ចនៃមូលដ្ឋានសុខាភិបាលត្រូវអនុវត្តជំហានដូចខាងក្រោម៖

ក- បំពេញព័ត៌មានអំពីកំណើតរស់ទៅក្នុងប្រព័ន្ធទិន្នន័យសុខាភិបាលឌីជីថល។

ខ- បោះពុម្ពលិខិតជូនដំណឹងអំពីកំណើតរស់ចំនួន ១(មួយ)ច្បាប់ ចេញពីប្រព័ន្ធទិន្នន័យសុខាភិបាលឌីជីថល ដើម្បីជូនម្ដាយ ឬឪពុក ឬសាច់ញាតិរបស់ទារក ពិនិត្យអំពីភាពត្រឹមត្រូវនៃព័ត៌មាន។

គ- ក្រោយពេលអនុវត្តជំហានព័ត៌មានត្រឹមត្រូវ ត្រូវបោះពុម្ពលិខិតជូនដំណឹងអំពីកំណើតរស់ចំនួន ២(ពីរ)ច្បាប់ និងចុះហត្ថលេខា ដោយរក្សាទុក ១(មួយ)ច្បាប់ នៅមូលដ្ឋានសុខាភិបាល និងប្រគល់ ១(មួយ)ច្បាប់ ជូនទៅម្ដាយ ឬឪពុក ឬសាច់ញាតិរបស់ទារក។

២- ក្នុងករណីមូលដ្ឋានសុខាភិបាលមិនអាចបំពេញដំណើរការតាមប្រព័ន្ធទិន្នន័យសុខាភិបាលឌីជីថល ដូចមានចែងនៅក្នុងចំណុចទី១ខាងលើ មុនពេលអនុញ្ញាតឱ្យទារក និង/ឬម្ដាយចាកចេញពីមូលដ្ឋានសុខាភិបាល ប្រធានមូលដ្ឋានសុខាភិបាល ឬបុគ្គលដែលត្រូវបានប្រគល់ភារកិច្ចនៃមូលដ្ឋានសុខាភិបាលត្រូវអនុវត្តជំហានដូចខាងក្រោម៖

ក- បំពេញព័ត៌មាននៅក្នុងទម្រង់នៃលិខិតជូនដំណឹងអំពីកំណើតរស់ជាក្រដាស ចំនួន ២(ពីរ) ច្បាប់។

ខ- រក្សាទុកលិខិតជូនដំណឹងអំពីកំណើតរស់ដែលបានចុះហត្ថលេខា ១(មួយ)ច្បាប់ នៅមូលដ្ឋានសុខាភិបាល និងប្រគល់ ១(មួយ)ច្បាប់ ជូនទៅម្ដាយ ឬឪពុក ឬសាច់ញាតិរបស់ទារក។

គ- បំពេញព័ត៌មានពីលិខិតជូនដំណឹងអំពីកំណើតរស់ទៅក្នុងប្រព័ន្ធទិន្នន័យសុខាភិបាលឌីជីថល មិនឱ្យយឺតជាងរយៈពេល ៣(បី)ថ្ងៃ ក្រោយសម្រាល។

ឃ- ក្រោយពេលអនុវត្តជំហានដូចខាងលើរួច ត្រូវផ្ដល់លេខសម្គាល់ទៅអ្នករាយការណ៍នៅពេលត្រឡប់មកពិនិត្យសុខភាព ឬតាមរយៈការហៅទូរសព្ទ ឬការផ្ញើសារ។

៣- ទិន្នន័យអំពីការជូនដំណឹងអំពីកំណើតរស់ដែលបានបញ្ចូលទៅក្នុងប្រព័ន្ធទិន្នន័យសុខាភិបាលឌីជីថល ត្រូវបញ្ជូនទៅអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម នៃក្រសួងមហាផ្ទៃ តាមរយៈសន្ទានកម្មនៃកម្មវិធីកុំព្យូទ័រដោយស្វ័យប្រវត្តិភ្លាមៗ។

**ប្រការ៧ .-**

ដំណើរការចេញ និងបញ្ជូនលិខិតជូនដំណឹងអំពីកំណើតរស់សម្រាប់កំណើតរស់ដែលកើតនៅក្រៅមូលដ្ឋានសុខាភិបាលត្រូវបានកំណត់ដូចខាងក្រោម៖

១- ក្នុងករណីកំណើតរស់កើតនៅក្រៅមូលដ្ឋានសុខាភិបាល ហើយម្ដាយ និងទារកមិនបានមកដល់មូលដ្ឋានសុខាភិបាលក្នុងរយៈពេល ៤៨(សែសិបប្រាំបី)ម៉ោង បន្ទាប់ពីការសម្រាលទារក បុគ្គលិកសុខាភិបាលត្រូវអនុវត្តជំហានដូចខាងក្រោម៖

ក- បុគ្គលិកសុខាភិបាលដែលផ្ដល់សេវាសម្រាលកូន ឬដឹងអំពីកំណើតរស់ ត្រូវប្រមូលព័ត៌មានដែលត្រូវបញ្ចូលក្នុងទម្រង់ជូនដំណឹងអំពីកំណើតរស់ ពីម្ដាយ ឬឪពុក ឬសាច់ញាតិរបស់ទារក។

ខ- បុគ្គលិកសុខាភិបាល ត្រូវផ្ដល់ព័ត៌មានពាក់ព័ន្ធនឹងកំណើតរស់ ជូនដល់មូលដ្ឋានសុខាភិបាលសាធារណៈនៅក្នុងរយៈពេល ២៤(ម្ភៃបួន)ម៉ោង បន្ទាប់ពីកំណើតរស់បានកើតឡើង ឬបន្ទាប់ពីបានដឹងពីកំណើតរស់។

គ- ប្រធានមូលដ្ឋានសុខាភិបាល ឬបុគ្គលដែលត្រូវបានប្រគល់ភារកិច្ច នៃមូលដ្ឋានសុខាភិបាលត្រូវបញ្ចូលព័ត៌មានទៅក្នុងប្រព័ន្ធទិន្នន័យសុខាភិបាលឌីជីថល និងបោះពុម្ពលិខិតជូនដំណឹងអំពីកំណើតរស់ ចេញពីប្រព័ន្ធទិន្នន័យសុខាភិបាលឌីជីថលចំនួន ២(ពីរ)ច្បាប់ និងចុះហត្ថលេខាមិនឱ្យយឺតជាង ៣(បី)ថ្ងៃ បន្ទាប់ពីទទួលបានព័ត៌មានអំពីកំណើតរស់។

ឃ- ប្រធានមូលដ្ឋានសុខាភិបាល ឬបុគ្គលដែលត្រូវបានប្រគល់ភារកិច្ច នៃមូលដ្ឋានសុខាភិបាលត្រូវរក្សាទុកលិខិតជូនដំណឹងអំពីកំណើតរស់ ១(មួយ)ច្បាប់ នៅមូលដ្ឋានសុខាភិបាល និង ១(មួយ)ច្បាប់ទៀតត្រូវប្រគល់ជូនបុគ្គលិកសុខាភិបាល ដើម្បីជូនទៅម្ដាយ ឬឪពុក ឬសាច់ញាតិរបស់ទារក។

២- ទិន្នន័យអំពីការជូនដំណឹងអំពីកំណើតរស់ដែលបានបញ្ចូលទៅក្នុងប្រព័ន្ធទិន្នន័យសុខាភិបាលឌីជីថល ត្រូវបញ្ជូនទៅអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម នៃក្រសួងមហាផ្ទៃ តាមរយៈសន្ទានកម្មនៃកម្មវិធីកុំព្យូទ័រដោយស្វ័យប្រវត្តិភ្លាមៗ។

## ជំពូកទី៤
## បែបបទ និងនីតិវិធី នៃការចេញលិខិតជូនដំណឹងអំពីមរណភាព និងលិខិតបញ្ជាក់វេជ្ជសាស្ត្រអំពីមូលហេតុនៃមរណភាព

**ប្រការ៨ .-**

ដំណើរការចេញ និងបញ្ជូនលិខិតជូនដំណឹងអំពីមរណភាពក្នុងករណីប្រក្រតី ដែលកើតនៅក្នុងមូលដ្ឋានសុខាភិបាលត្រូវបានកំណត់ដូចខាងក្រោម៖

១- ក្នុងករណីមរណភាពដោយសារមូលហេតុប្រក្រតី ហើយកើតឡើងនៅក្នុងមូលដ្ឋានសុខាភិបាល ឬកំពុងធ្វើដំណើរទៅមូលដ្ឋានសុខាភិបាល និងមុនពេលអនុញ្ញាតឱ្យយកសាកសពចេញពីមូលដ្ឋានសុខាភិបាល ប្រធានមូលដ្ឋានសុខាភិបាល ឬបុគ្គលដែលត្រូវបានប្រគល់ភារកិច្ចនៃមូលដ្ឋានសុខាភិបាលត្រូវអនុវត្តជំហានដូចខាងក្រោម៖

ក- បំពេញព័ត៌មានអំពីមរណភាព ទៅក្នុងប្រព័ន្ធទិន្នន័យសុខាភិបាលឌីជីថល។

ខ- បោះពុម្ពលិខិតជូនដំណឹងអំពីមរណភាពចំនួន ១(មួយ)ច្បាប់ ចេញពីប្រព័ន្ធទិន្នន័យសុខាភិបាលឌីជីថល ដើម្បីជូនទៅម្ដាយ ឬឪពុក ឬសហព័ទ្ធ ឬញាតិជានីតិជនរបស់មរណជនពិនិត្យអំពីភាពត្រឹមត្រូវនៃព័ត៌មាន។

គ- ប្រសិនបើព័ត៌មានត្រឹមត្រូវអស់ហើយ ត្រូវបោះពុម្ពលិខិតជូនដំណឹងអំពីមរណភាពចំនួន ២(ពីរ)ច្បាប់ និងចុះហត្ថលេខា ដោយរក្សាលិខិតជូនដំណឹងអំពីមរណភាព ១(មួយ)ច្បាប់ នៅមូលដ្ឋានសុខាភិបាល និងប្រគល់ ១(មួយ)ច្បាប់ ជូនទៅម្ដាយ ឬឪពុក ឬសហព័ទ្ធ ឬញាតិជានីតិជនរបស់មរណជន។

២- ប្រសិនបើអ្នកជំងឺទទួលមរណភាពក្នុងអំឡុងពេលកំពុងបញ្ជូនពីមូលដ្ឋានសុខាភិបាលមួយទៅមូលដ្ឋានសុខាភិបាលមួយផ្សេងទៀត មូលដ្ឋានសុខាភិបាលដែលបញ្ជូនអ្នកជំងឺត្រូវទទួលខុសត្រូវក្នុងការបំពេញការជូនដំណឹងអំពីមរណភាពស្របតាមជំហាននានាក្នុងចំណុចទី១ខាងលើ។

៣- ក្នុងករណីមូលដ្ឋានសុខាភិបាលមិនអាចបំពេញដំណើរការតាមប្រព័ន្ធទិន្នន័យសុខាភិបាលឌីជីថល ដូចមានចែងនៅក្នុងចំណុចទី១ខាងលើ មុនពេលអនុញ្ញាតឱ្យយកសាកសពចេញពីមូលដ្ឋានសុខាភិបាល ប្រធានមូលដ្ឋានសុខាភិបាល ឬបុគ្គលដែលត្រូវបានប្រគល់ភារកិច្ចនៃមូលដ្ឋានសុខាភិបាលត្រូវអនុវត្តជំហានដូចខាងក្រោម៖

ក- បំពេញព័ត៌មាននៅក្នុងទម្រង់នៃលិខិតជូនដំណឹងអំពីមរណភាព ជាក្រដាស ចំនួន ២(ពីរ)ច្បាប់។

ខ- រក្សាទុកទម្រង់នៃលិខិតជូនដំណឹងអំពីមរណភាពដែលបានចុះហត្ថលេខា ១(មួយ)ច្បាប់ នៅមូលដ្ឋានសុខាភិបាល និងប្រគល់ ១(មួយ)ច្បាប់ ជូនទៅម្ដាយ ឬឪពុក ឬសហព័ទ្ធ ឬញាតិជានីតិជនរបស់មរណជន។

គ- បំពេញព័ត៌មាននៅក្នុងលិខិតជូនដំណឹងអំពីមរណភាព ទៅក្នុងប្រព័ន្ធទិន្នន័យសុខាភិបាលឌីជីថល មិនឱ្យយឺតជាងរយៈពេល ៣(បី)ថ្ងៃ ក្រោយទទួលមរណភាព។

៤- ទិន្នន័យអំពីការជូនដំណឹងអំពីមរណភាពដែលបានបញ្ចូលទៅក្នុងប្រព័ន្ធទិន្នន័យសុខាភិបាលឌីជីថល ត្រូវបញ្ជូនទៅអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម នៃក្រសួងមហាផ្ទៃ តាមរយៈសន្ទានកម្មនៃកម្មវិធីកុំព្យូទ័រដោយស្វ័យប្រវត្តិភ្លាមៗ។

៥- ចំពោះករណីមរណភាពមិនអាចកំណត់ថាប្រក្រតីដែលកើតឡើងនៅក្នុងមូលដ្ឋានសុខាភិបាល ឬអំឡុងពេលធ្វើដំណើរទៅមូលដ្ឋានសុខាភិបាល ប្រធានមូលដ្ឋានសុខាភិបាល ឬគ្រូពេទ្យនៃមូលដ្ឋានសុខាភិបាល ត្រូវរាយការណ៍អំពីមរណភាពនោះទៅប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ ដើម្បីសហការចូលរួមពិនិត្យអំពីករណីមរណភាពនោះ។ ប្រសិនបើមរណភាពនោះត្រូវបានកំណត់ជាករណីដែលមានភាពខុសប្រក្រតី ឬគួរឱ្យសង្ស័យត្រូវអនុវត្តតាមនីតិវិធីដូចមានកំណត់ក្នុងប្រការ១១ នៃប្រកាសអន្តរក្រសួងនេះ។

**ប្រការ៩ .-**

ដំណើរការចេញ និងបញ្ជូនលិខិតជូនដំណឹងអំពីមរណភាព សម្រាប់មរណភាពប្រក្រតីដែលកើតនៅក្រៅមូលដ្ឋានសុខាភិបាលត្រូវបានកំណត់ដូចខាងក្រោម៖

១- ក្នុងករណីមានមរណភាពប្រក្រតីកើតឡើងនៅក្រៅមូលដ្ឋានសុខាភិបាល បុគ្គលទាំងឡាយណាដែលដឹងអំពីមរណភាពនេះ ត្រូវរាយការណ៍ភ្លាមៗអំពីមរណភាពជូនដល់នាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ នៃឃុំ សង្កាត់ដែលមរណភាពបានកើតឡើង។

២- នាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ ត្រូវធ្វើការទាក់ទងភ្លាមៗទៅមូលដ្ឋានសុខាភិបាលសាធារណៈនៅជិតបំផុត។

៣- ប្រធានមូលដ្ឋានសុខាភិបាលសាធារណៈ ត្រូវចាត់បញ្ជូនគ្រូពេទ្យ ឬមន្ត្រីសុខាភិបាល ១(មួយ)រូប ពីមូលដ្ឋានសុខាភិបាលក្នុងរយៈពេល ៣(បី)ម៉ោង ក្រោយពេលទទួលបានព័ត៌មានអំពីមរណភាព។

៤- នាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ និងគ្រូពេទ្យ ឬមន្ត្រីសុខាភិបាលដែលត្រូវបានប្រគល់ភារកិច្ច ត្រូវធ្វើដំណើរទៅកន្លែងដែលសាកសពរបស់មរណជនស្ថិតនៅ និងផ្តល់ការបញ្ជាក់រួមគ្នាថាមរណភាពមួយបានកើតឡើង ដោយសារមូលហេតុប្រក្រតី និងមិនមានការសង្ស័យ។

៥- គ្រូពេទ្យ ឬមន្ត្រីសុខាភិបាលដែលត្រូវបានប្រគល់ភារកិច្ច ត្រូវបំពេញព័ត៌មាន និងចុះហត្ថលេខាលើទម្រង់ជូនដំណឹងអំពីមរណភាពជាក្រដាស ដោយមានហត្ថលេខាអមរបស់នាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ ដូចកំណត់ក្នុងឧបសម្ព័ន្ធទី៣ នៃប្រកាសអន្តរក្រសួងនេះ។ លិខិតជូនដំណឹងអំពីមរណភាពនេះ ត្រូវប្រគល់ជូនទៅម្តាយ ឬឪពុក ឬសហព័ទ្ធ ឬញាតិជានីតិជនរបស់មរណជនចំនួន ១(មួយ)ច្បាប់ និងរក្សាទុកនៅប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ចំនួន ១(មួយ)ច្បាប់ និង ១(មួយ)ច្បាប់ទៀត រក្សាទុកនៅមូលដ្ឋានសុខាភិបាល។

៦- គ្រូពេទ្យ ឬមន្ត្រីសុខាភិបាលដែលត្រូវបានប្រគល់ភារកិច្ចជូន ត្រូវបញ្ចូលព័ត៌មានអំពីមរណភាពទៅក្នុងប្រព័ន្ធទិន្នន័យសុខាភិបាលឌីជីថល បន្ទាប់មកបោះពុម្ពលិខិតជូនដំណឹងអំពីមរណភាពចំនួន ១(មួយ)ច្បាប់ ដើម្បីរក្សាទុកនៅមូលដ្ឋានសុខាភិបាល។

**ប្រការ១០ .-**

ដំណើរការចេញលិខិតបញ្ជាក់វេជ្ជសាស្ត្រអំពីមូលហេតុនៃមរណភាព ក្នុងករណីមរណភាពប្រក្រតីត្រូវបានកំណត់ដូចខាងក្រោម៖

១- ក្នុងករណីមរណភាពកើតឡើងនៅក្នុងមូលដ្ឋានសុខាភិបាលមានលក្ខណៈប្រក្រតី ឬមិនមានការសង្ស័យ ប្រធានមូលដ្ឋានសុខាភិបាល ឬគ្រូពេទ្យនៃមូលដ្ឋានសុខាភិបាលត្រូវបំពេញលិខិតបញ្ជាក់វេជ្ជសាស្ត្រអំពីមូលហេតុនៃមរណភាពនៅក្នុងទម្រង់ នៃលិខិតបញ្ជាក់វេជ្ជសាស្ត្រអំពីមូលហេតុនៃ

មរណភាពដែលកំណត់ដោយក្រសួងសុខាភិបាល។ ប្រសិនបើពុំអាចបំពេញលិខិតបញ្ជាក់វេជ្ជសាស្ត្រមូលហេតុនៃមរណភាពបានទេ មូលដ្ឋានសុខាភិបាលត្រូវចេញត្រឹមលិខិតជូនដំណឹងអំពីមរណភាពតែប៉ុណ្ណោះ។

២- ក្នុងករណីមរណភាពដែលកើតឡើងមានលក្ខណៈប្រក្រតី ឬមិនមានការសង្ស័យ ហើយសពត្រូវបាននាំយកមកមូលដ្ឋានសុខាភិបាល ប្រធានមូលដ្ឋានសុខាភិបាល ឬគ្រូពេទ្យដែលត្រូវបានប្រគល់ភារកិច្ចជូន ត្រូវខិតខំបំពេញលិខិតបញ្ជាក់វេជ្ជសាស្ត្រអំពីមូលហេតុនៃមរណភាព ប្រសិនបើមានព័ត៌មានគ្រប់គ្រាន់ពាក់ព័ន្ធនឹងប្រវត្តិរបស់មរណជន ដើម្បីកំណត់អំពីមូលហេតុនៃមរណភាព។ ប្រសិនបើពុំអាចបំពេញទម្រង់លិខិតបញ្ជាក់វេជ្ជសាស្ត្រអំពីមូលហេតុនៃមរណភាពបានទេ មូលដ្ឋានសុខាភិបាលត្រូវចេញត្រឹមលិខិតជូនដំណឹងអំពីមរណភាពតែប៉ុណ្ណោះ។

៣- ក្នុងករណីមរណភាពដែលកើតឡើងនៅផ្ទះមានលក្ខណៈប្រក្រតី និងមិនមានការសង្ស័យ នាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ និងមន្ត្រីសុខាភិបាលជំនាញ និង/ឬគ្រូពេទ្យព្យាបាល ត្រូវសហការគ្នាបំពេញលិខិតបញ្ជាក់វេជ្ជសាស្ត្រអំពីមូលហេតុនៃមរណភាព ដែលមានព័ត៌មានគ្រប់គ្រាន់ពាក់ព័ន្ធនឹងប្រវត្តិវេជ្ជសាស្ត្ររបស់មរណជន ដើម្បីកំណត់អំពីមូលហេតុនៃមរណភាព។ ក្នុងករណីដែលគ្រូពេទ្យព្យាបាល ឬមន្ត្រីសុខាភិបាលជំនាញ មិនអាចបំពេញលិខិតបញ្ជាក់វេជ្ជសាស្ត្រអំពីមូលហេតុនៃមរណភាពបានទេ ត្រូវចេញត្រឹមលិខិតជូនដំណឹងអំពីមរណភាពតែប៉ុណ្ណោះ។

៤- ករណីដូចមានចែងក្នុងចំណុចទី១ ទី២ និងទី៣ខាងលើ គ្រូពេទ្យ ឬបុគ្គលិកសុខាភិបាលដែលត្រូវបានប្រគល់ភារកិច្ចជូន ត្រូវបញ្ចូលទិន្នន័យនៃលិខិតបញ្ជាក់វេជ្ជសាស្ត្រអំពីមូលហេតុនៃមរណភាពទៅក្នុងប្រព័ន្ធទិន្នន័យសុខាភិបាលឌីជីថល ក្នុងរយៈពេល ២៤(ម្ភៃបួន)ម៉ោង បន្ទាប់ពីទទួលបានលិខិតបញ្ជាក់វេជ្ជសាស្ត្រអំពីមូលហេតុនៃមរណភាព។

**ប្រការ១១ .-**

ដំណើរការចេញលិខិតជូនដំណឹងអំពីមរណភាព និងលិខិតបញ្ជាក់វេជ្ជសាស្ត្រអំពីមូលហេតុនៃមរណភាពនៅក្នុងករណីមរណភាពខុសប្រក្រតីត្រូវបានកំណត់ដូចខាងក្រោម៖

១- ក្នុងករណីមរណភាពដែលកើតឡើងដោយសារមូលហេតុខុសប្រក្រតី ឬគួរឱ្យសង្ស័យដែលត្រូវបានស៊ើបអង្កេតដោយមន្ត្រីនគរបាល និងគ្រូពេទ្យនៃគណៈកម្មការសល្យកោសល្យវិច័យ គ្រូពេទ្យជាសមាជិកគណៈកម្មការសល្យកោសល្យវិច័យ ត្រូវជានាថាទម្រង់នៃលិខិតជូនដំណឹងអំពីមរណភាពត្រូវបានបំពេញភ្លាមៗនៅពេលទទួលបានព័ត៌មានចាំបាច់។ គ្រូពេទ្យនៃគណៈកម្មការសល្យកោសល្យវិច័យ ឬបុគ្គលដទៃទៀតដែលត្រូវបានប្រគល់ភារកិច្ចជូន ត្រូវបញ្ចូលព័ត៌មានពីលិខិតជូនដំណឹងអំពីមរណភាព ទៅក្នុងប្រព័ន្ធទិន្នន័យសុខាភិបាលឌីជីថល បន្ទាប់មកត្រូវបោះពុម្ពលិខិតជូនដំណឹងអំពីមរណភាពចំនួន ២(ពីរ)ច្បាប់ ដោយរក្សាទុក ១(មួយ) ច្បាប់ នៅមូលដ្ឋានសុខាភិបាល និងប្រគល់ ១(មួយ)ច្បាប់ ជូនទៅម្ដាយ ឬឪពុក ឬសហព័ទ្ធ ឬញាតិជានីតិជនរបស់មរណជន។

២- ប្រសិនបើពុំមានម្ដាយ ឬឪពុក ឬសហព័ទ្ធ ឬសាច់ញាតិរបស់មរណជនផ្ដល់ព័ត៌មានអំពីមរណភាព មន្ត្រីនគរបាលដែលទទួលបន្ទុកសំណុំរឿង ត្រូវបំពេញតួនាទីជាអ្នករាយការណ៍សម្រាប់ករណីមរណភាពនេះ និងត្រូវរាយការណ៍អំពីមរណភាពទៅមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់។

៣- នៅក្នុងរយៈពេល ២៤(ម្ភៃបួន)ម៉ោង បន្ទាប់ពីបានកំណត់អំពីមូលហេតុ និងលក្ខណៈនៃមរណភាពរបស់មរណជន គ្រូពេទ្យនៃគណៈកម្មការសល្យកោសល្យវិច័យ ឬគ្រូពេទ្យ ឬបុគ្គលិកសុខាភិបាលដែលត្រូវបានប្រគល់ភារកិច្ច ត្រូវបញ្ចូលទិន្នន័យនៅក្នុងលិខិតបញ្ជាក់វេជ្ជសាស្ត្រអំពីមូលហេតុនៃមរណភាពទៅក្នុងប្រព័ន្ធទិន្នន័យសុខាភិបាលឌីជីថល។

**ប្រការ១២ .-**

ការចេញលិខិតជូនដំណឹងអំពីមរណភាពរបស់បុគ្គលដែលមិនស្គាល់អត្តសញ្ញាណច្បាស់លាស់ ត្រូវបានកំណត់ដូចខាងក្រោម៖

១- ក្នុងករណីដែលមរណភាពត្រូវបានស៊ើបអង្កេតដោយមន្ត្រីនគរបាល និងគ្រូពេទ្យនៃគណៈកម្មការសល្យកោសល្យវិច័យ ស្របតាមប្រការ១១ នៃប្រកាសអន្តរក្រសួងនេះ ហើយមិនអាចកំណត់អត្តសញ្ញាណរបស់មរណជនបាន គ្រូពេទ្យនៃគណៈកម្មការសល្យកោសល្យវិច័យ ឬបុគ្គលដែលត្រូវបានប្រគល់ភារកិច្ច ត្រូវបញ្ចូលព័ត៌មានឱ្យបានច្រើនបំផុតដែលបានដឹងអំពីមរណជននោះទៅក្នុងប្រព័ន្ធទិន្នន័យសុខាភិបាលឌីជីថល និងបោះពុម្ពលិខិតជូនដំណឹងអំពីមរណភាព។

២- ប្រធានមូលដ្ឋានសុខាភិបាល ឬបុគ្គលដែលត្រូវបានប្រគល់ភារកិច្ចនៃមូលដ្ឋានសុខាភិបាល ត្រូវចេញលិខិតជូនដំណឹងអំពីមរណភាពចំនួន ១(មួយ)ច្បាប់ ជូនដល់មន្ត្រីនគរបាលដែលទទួលបន្ទុកសំណុំរឿង។ ករណីនេះ មន្ត្រីនគរបាលដែលទទួលបន្ទុកសំណុំរឿងត្រូវបំពេញតួនាទីជាអ្នករាយការណ៍សម្រាប់មរណភាពនេះ និងបញ្ជូនលិខិតជូនដំណឹងអំពីមរណភាពជូនទៅមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់ រួមជាមួយនឹងលេខកំណត់ត្រាស៊ើបអង្កេត។

**ប្រការ១៣ .-**

ការកំណត់កូដ និងការបញ្ជូនមូលហេតុនៃមរណភាពទៅអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម នៃក្រសួងមហាផ្ទៃ ត្រូវបានកំណត់ដូចខាងក្រោម៖

១- ក្រសួងសុខាភិបាលត្រូវកំណត់កូដនូវរាល់ទិន្នន័យមូលហេតុនៃមរណភាពតាមលិខិតបញ្ជាក់វេជ្ជសាស្ត្រអំពីមូលហេតុនៃមរណភាព ដែលបានបញ្ចូលទៅក្នុងប្រព័ន្ធទិន្នន័យសុខាភិបាលឌីជីថល ដោយយោងតាមការចាត់ថ្នាក់ជំងឺជាលក្ខណៈអន្តរជាតិ និងកំណត់អំពីមូលហេតុឫសគល់ដើមនៃមរណភាព។

២- បន្ទាប់ពីទិន្នន័យអំពីមូលហេតុនៃមរណភាពត្រូវបានកំណត់កូដរួចរាល់ហើយ ក្រសួងសុខាភិបាលត្រូវបញ្ជូនទៅអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម នៃក្រសួងមហាផ្ទៃ តាមរយៈសន្ទានកម្មនៃកម្មវិធីកុំព្យូទ័រដែលត្រូវបានកំណត់នូវ៖

ក- មូលហេតុឫសគល់ដើមនៃមរណភាពក្នុងទម្រង់ជាអក្សរ និងកូដ នៃការចាត់ថ្នាក់ជំងឺជាលក្ខណៈអន្តរជាតិ។

ខ- ការបែងចែកចំណាត់ប្រភេទនៃលក្ខណៈមរណភាពរបស់អង្គការសុខភាពពិភពលោក។

៣- បន្ទាប់ពីទទួលបានមូលហេតុឫសគល់ចុងក្រោយនៃមរណភាព និងការបែងចែកចំណាត់ថ្នាក់ប្រភេទនៃលក្ខណៈមរណភាពរបស់អង្គការសុខភាពពិភពលោក អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម នៃក្រសួងមហាផ្ទៃ ត្រូវបញ្ចូលមូលហេតុឫសគល់ចុងក្រោយនៃមរណភាព និងបែងចែកចំណាត់ប្រភេទនៃលក្ខណៈមរណភាពរបស់អង្គការសុខភាពពិភពលោក ទៅក្នុងកំណត់ត្រាចុះបញ្ជីមរណភាព ដោយប្រើប្រាស់លេខសម្គាល់ ដែលបង្កើតចេញពីប្រព័ន្ធទិន្នន័យសុខាភិបាលឌីជីថល។

**ប្រការ១៤ ._**

ការសាកសួរផ្ទាល់មាត់ ដើម្បីបញ្ជាក់មូលហេតុនៃមរណភាពត្រូវបានកំណត់ដូចខាងក្រោម៖

១- ប្រសិនបើមិនអាចបំពេញលិខិតបញ្ជាក់វេជ្ជសាស្ត្រអំពីមូលហេតុនៃមរណភាព សម្រាប់មរណភាពប្រក្រតី ស្របតាមប្រការ១០ នៃប្រកាសអន្តរក្រសួងនេះបាន ក្រសួងសុខាភិបាលមានសិទ្ធិក្នុងការកំណត់មូលហេតុនៃមរណភាពដែលបានកើតឡើង ដោយការសាកសួរផ្ទាល់មាត់ក្នុងការកំណត់រកមូលហេតុនៃមរណភាព។

២- ក្រសួងសុខាភិបាលត្រូវបញ្ជូនមូលហេតុនៃមរណភាព និងព័ត៌មានដែលពាក់ព័ន្ធនឹងការសាកសួរផ្ទាល់មាត់ ជាមួយអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម នៃក្រសួងមហាផ្ទៃ ដើម្បីប្រើប្រាស់ក្នុងគោលបំណងផលិតស្ថិតិអត្រានុកូលដ្ឋាន ទិន្នន័យរដ្ឋបាល និងការរៀបចំផែនការនានា។

៣- ទម្រង់ បែបបទ និងនីតិវិធីនៃការកំណត់មូលហេតុនៃមរណភាព ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**ប្រការ១៥ ._**

អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល អគ្គនាយកនៃអគ្គនាយកដ្ឋាន អគ្គាធិការ ប្រធានអង្គភាពពាក់ព័ន្ធនៃក្រសួងមហាផ្ទៃ និងក្រសួងសុខាភិបាល មន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ១១ រោច ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែមករា ឆ្នាំ២០២៦

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**អគ្គបណ្ឌិតសភាចារ្យ ស សុខា**

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

**សាស្ត្រាចារ្យ ឈាង រ៉ា**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ១៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធទី១ នៃប្រកាសអន្តរក្រសួងលេខ ៤៧៧/២៦ ប្រក ចុះថ្ងៃទី ១៣ ខែ មេសា ឆ្នាំ២០២៦
ស្តីពីការជូនដំណឹងអំពីកំណើតរស់ និងមរណភាពទៅមន្ត្រីអត្រានុកូលដ្ឋាន

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## លិខិតជូនដំណឹងអំពីកំណើតរស់

លេខចេញ៖........................................ លេខសម្គាល់៖........................................

| | | |
|---|---|---|
| ប្រភេទមូលដ្ឋានសុខាភិបាល៖ | ប្រភេទទីកន្លែងកំណើត៖<br>☐ នៅមូលដ្ឋានសុខាភិបាល ☐ នៅផ្ទះ<br>☐ ផ្សេងៗ សូមបញ្ជាក់................................ | លេខកូដមូលដ្ឋានសុខាភិបាល៖<br>☐☐☐☐☐☐ |

ឈ្មោះទារក៖ នាមត្រកូល.............................................. នាមខ្លួន.............................................. ☐ មិនទាន់មានឈ្មោះ

| ភេទទារក៖ | ទម្ងន់ទារកកើត (ជាក្រាម)៖ | ប្រភេទកំណើតទារក៖ | ថ្ងៃខែឆ្នាំកំណើត៖ | ម៉ោងកើត (២៤ម៉ោង)៖ |
|---|---|---|---|---|
| ☐ ប្រុស<br>☐ ស្រី | ☐☐☐☐ | ☐ កូនទោល ☐ ភ្លោះពីរ<br>☐ ភ្លោះបី ☐ ភ្លោះបួន<br>☐ ផ្សេងៗ សូមបញ្ជាក់<br>.................................... | ☐☐☐☐☐☐☐☐ | ☐☐☐☐☐ |

| | |
|---|---|
| ទីកន្លែងកំណើត (ទីតាំងមូលដ្ឋានសុខាភិបាល ឬផ្ទះ ឬកន្លែងផ្សេងៗ)៖<br>ភូមិ..........................................ឃុំ/សង្កាត់៖..........................................<br>ក្រុង/ស្រុក/ខណ្ឌ៖......................................រាជធានី/ខេត្ត៖............................ | ប្រភេទអ្នកផ្តល់សេវាសម្រាលកូន៖<br>☐ វេជ្ជបណ្ឌិតវះកាត់ ☐ វេជ្ជបណ្ឌិត ☐ ឆ្មប<br>☐ ផ្សេងៗ សូមបញ្ជាក់.......................... |

**ព័ត៌មានឪពុកម្តាយ**

| | |
|---|---|
| ឈ្មោះម្តាយ៖<br>នាមត្រកូល..........................................<br>នាមខ្លួន..........................................<br>លេខទូរសព្ទម្តាយ.................................. | លំនៅឋានបច្ចុប្បន្នរបស់ម្តាយ៖<br>ភូមិ..........................................ឃុំ/សង្កាត់៖..........................................<br>ក្រុង/ស្រុក/ខណ្ឌ៖......................................រាជធានី/ខេត្ត៖.................................. |

ឈ្មោះឪពុក៖
នាមត្រកូល.......................................... នាមខ្លួន.......................................... លេខទូរសព្ទឪពុក..................................

ថ្ងៃ....................ខែ...........ឆ្នាំ........................ព.ស. ២៥៦....
........................ថ្ងៃទី........ខែ..........ឆ្នាំ ២០......
គ្រូពេទ្យ/មន្ត្រីសុខាភិបាល
ហត្ថលេខា និងឈ្មោះ

បានឃើញ និងអនុម័ត
ប្រធានមូលដ្ឋានសុខាភិបាល

ឧបសម្ព័ន្ធទី២ នៃប្រកាសអន្តរក្រសួងលេខ ៤៧៧២ ប្រក ចុះថ្ងៃទី ១៣ ខែ មេសា ឆ្នាំ២០២៦
ស្តីពីការជូនដំណឹងអំពីកំណើតរស់ និងមរណភាពទៅមន្ត្រីអត្រានុកូលដ្ឋាន

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## លិខិតជូនដំណឹងអំពីមរណភាពដែលកើតឡើងនៅក្នុងមូលដ្ឋានសុខាភិបាល

លេខចេញ៖.............................................. លេខសម្គាល់៖..............................................

<table>
<tr><td colspan="3">ប្រភេទមូលដ្ឋានសុខាភិបាល៖<br>☐ សាធារណៈ៖ ..........................................................<br>☐ ឯកជន៖..........................................................</td><td colspan="2">លេខកូដមូលដ្ឋានសុខាភិបាល៖<br>☐☐☐☐☐☐</td></tr>
<tr><td colspan="2">ឈ្មោះមរណជន *៖<br>នាមត្រកូល៖..........................................................<br>នាមខ្លួន៖..........................................................<br>*ប្រសិនបើអ្នកស្លាប់ទើបនឹងកើត ដោយគ្មានឈ្មោះ ចូរសរសេរ "កូនរបស់ <ឈ្មោះម្តាយ>"</td><td colspan="2">ថ្ងៃខែឆ្នាំមរណភាព៖<br>☐☐☐☐☐☐☐☐</td><td>ម៉ោងមរណភាព (២៤ម៉ោង)៖<br>☐☐☐☐☐</td></tr>
<tr><td>ថ្ងៃខែឆ្នាំកំណើត៖<br>☐☐☐☐☐☐☐☐</td><td colspan="2">អាយុ បើមិនមានថ្ងៃខែឆ្នាំកំណើត៖......................<br>ឬតិចជាង ២៤ម៉ោង៖............ម៉ោង.............នាទី</td><td>ភេទមរណជន៖<br>☐ ប្រុស<br>☐ ស្រី</td><td>ប្រភេទនៃមរណភាព៖<br>☐ ប្រក្រតី<br>☐ ខុសប្រក្រតី</td></tr>
<tr><td colspan="5">លំនៅឋានបច្ចុប្បន្នរបស់មរណជន (ឬលំនៅឋានបច្ចុប្បន្នរបស់ម្តាយបើមរណជនជាទារក)៖<br>ភូមិ.........................ឃុំ/សង្កាត់៖............................ក្រុង/ស្រុក/ខណ្ឌ៖................................រាជធានី/ខេត្ត៖.........................</td></tr>
<tr><td>☐ សង្ស័យមរណភាពមាតា</td><td colspan="4">លេខទូរសព្ទ ញាតិមរណជន ឬអ្នករាយការណ៍៖..........................................................</td></tr>
</table>

ថ្ងៃ.......................ខែ............ឆ្នាំ..........................ព.ស. ២៥៦....
..........................ថ្ងៃទី........ខែ...........ឆ្នាំ ២០.......
គ្រូពេទ្យ/មន្ត្រីសុខាភិបាល
ហត្ថលេខា និងឈ្មោះ

បានឃើញ និងអនុម័ត
ប្រធានមូលដ្ឋានសុខាភិបាល

ឧបសម្ព័ន្ធទី៣ នៃប្រកាសអន្តរក្រសួងលេខ ៤៧/៧៤ ប្រក ចុះថ្ងៃទី ១៣ ខែ មេសា ឆ្នាំ២០២៦
ស្តីពីការជូនដំណឹងអំពីកំណើតរស់ និងមរណភាពទៅមន្ត្រីអត្រានុកូលដ្ឋាន

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## លិខិតជូនដំណឹងអំពីមរណភាពដែលកើតឡើងនៅក្រៅមូលដ្ឋានសុខាភិបាល

លេខចេញ៖.............................................. លេខសម្គាល់៖..............................................

| | | | |
|---|---|---|---|
| ប្រភេទទីកន្លែងមរណភាព៖<br>☐ នៅផ្ទះ<br>☐ ផ្សេងៗ សូមបញ្ជាក់៖..............................<br>.............................................. | | | លេខកូដមូលដ្ឋានសុខាភិបាល៖<br>☐☐☐☐☐☐ |
| ឈ្មោះមរណជន *៖<br>នាមត្រកូល៖..............................<br>នាមខ្លួន៖..............................<br>**ប្រសិនបើអ្នកស្លាប់ទើបនឹងកើត ដោយគ្មានឈ្មោះ ចូរសរសេរ "កូនរបស់ <ឈ្មោះម្តាយ>"* | ថ្ងៃខែឆ្នាំមរណភាព៖<br>☐☐☐☐☐☐☐☐ | | ម៉ោងមរណភាព (២៤ម៉ោង)៖<br>☐☐☐☐☐ |
| ថ្ងៃខែឆ្នាំកំណើត៖<br>☐☐☐☐☐☐☐☐ | អាយុ បើមិនមានថ្ងៃខែឆ្នាំកំណើត៖....................<br>ឬតិចជាង ២៤ម៉ោង៖............ម៉ោង.............នាទី | ភេទមរណជន៖<br>☐ ប្រុស<br>☐ ស្រី | ប្រភេទនៃមរណភាព៖<br>☐ ប្រក្រតី<br>☐ ខុសប្រក្រតី |
| លំនៅឋានបច្ចុប្បន្នរបស់មរណជន (ឬលំនៅឋានបច្ចុប្បន្នរបស់ម្តាយបើមរណជនជាទារក)៖<br>ភូមិ..........................ឃុំ/សង្កាត់៖............................ក្រុង/ស្រុក/ខណ្ឌ៖...............................រាជធានី/ខេត្ត៖........................ | | | |
| ☐ សង្ស័យមរណភាពមាតា | លេខទូរសព្ទ ញាតិមរណជន ឬអ្នករាយការណ៍៖.............................................................. | | |

ថ្ងៃ.......................ខែ............ឆ្នាំ..........................ព.ស. ២៥៦....
...........................ថ្ងៃទី........ខែ...........ឆ្នាំ ២០.......
គ្រូពេទ្យ/មន្ត្រីសុខាភិបាល
ហត្ថលេខា និងឈ្មោះ

នាយប៉ុស្តិ៍នគរបាលរដ្ឋបាល....................
ហត្ថលេខា និងឈ្មោះ

បានឃើញ និងអនុម័ត
ប្រធានមូលដ្ឋានសុខាភិបាល

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation

លេខ: ០៤០ [illegible]

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០២៦

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញអនុក្រឹត្យលេខ១៥៣ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការបង្កើតឃុំត្រពាំងសែនជ័យ ស្រុកស្នួល ខេត្តក្រចេះ របស់រាជរដ្ឋាភិបាល
- យោងលិខិតលេខ១៥៦៣/១០ ក.អ.ក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១០ ស្តីពីការវិនិយោគលើគម្រោងបង្កើតរោងចក្រកែច្នៃជ័រកៅស៊ូ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងលិខិតលេខ១០៩៨/២៥ គ.វ.ក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៥ ស្តីពីការប្តូរប្រធានក្រុមប្រឹក្សាភិបាលរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងសំណើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២៥ របស់ក្រុមហ៊ុន វៀតណាម (កម្ពុជា) អ៊ីខននើមី ត្រេដ អេន អ៊ិនដាសស្រ្ទី ខមភេនី លីមីធីត (វីខេតធី)

### សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន វៀតណាម (កម្ពុជា) អ៊ីខននើមី ត្រេដ អេន អ៊ិនដាសស្ទ្រី ខមភេនី លីមីធីត (វីខេតធី) **(VIETNAM (KAMPUCHEA) ECONOMY TRADE AND INDUSTRY COMPANY LIMITED (VKETI) CO., LTD.)** តំណាងដោយលោក **LE THANH NGHI** សញ្ជាតិវៀតណាម កាន់លិខិតឆ្លងដែនលេខ **C9712711** ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០២២ បង្កើតរោងចក្រកែច្នៃជ័រកៅស៊ូ ដែលមានទីតាំងស្ថិតនៅភូមិត្រពាំងសែនជ័យខាងជើង ឃុំត្រពាំងសែនជ័យ ស្រុកស្នួល ខេត្តក្រចេះ។

| **ឈ្មោះផលិតផល** | **លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code** |
| --- | --- |
| ជ័រកៅស៊ូ (កែច្នៃ) | ២២១៩ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកស្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះ រោងចក្រ និងសិប្បកម្ម។

ស្លាកឈ្មោះរោងចក្រ៖ " **រោងចក្រកែច្នៃជ័រកៅស៊ូ វៀតណាម (កម្ពុជា) អ៊ីខននើមី គ្រេដ អេន អ៊ិនដាសស្ទ្រី ខមភេនី លីមីធីត (វីខេតជី)** "

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងបទប្បញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហនៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣-ថ្មី មាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណីប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាព នៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ស្របតាមមាត្រា១៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។ ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឱ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រយៈពេល០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** ប្រកាសបង្កើតរោងចក្រលេខ១៦១ ឧស.កឧ.ប្រក.០៥ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៨ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងលិខិតលេខ១១៨៣៣ ឧវបន.កឧ.លស ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២៥ ស្តីពីការប្តូរប្រធានក្រុមប្រឹក្សាភិបាល របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ១៥៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តក្រចេះ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះតាមមុខការរៀងៗខ្លួន។

**ប្រការ១៦៖** ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ជ.រដ្ឋមន្ត្រី

រដ្ឋលេខាធិការ

**បណ្ឌិត ទឹម ស៊ីនី**

**ចម្លងជូន៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ក្រសួងពាណិជ្ជកម្ម

-ក្រសួងបរិស្ថាន

-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-រាជកិច្ច

-ខុទ្ទកាល័យរដ្ឋមន្ត្រី

-សាលាខេត្តក្រចេះ

-មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តក្រចេះ "ដើម្បីជូនជ្រាប"

-ដូចប្រការ១៥ "ដើម្បីអនុវត្ត"

-ឯកសារ-កាលប្បវត្តិ

រក្សាសិទ្ធិនិងបោះពុម្ពដោយនាយកដ្ឋានរាជកិច្ច នៃ
អគ្គនាយកដ្ឋានរាជកិច្ចនិងបណ្ណសារជាតិ
ទីស្តីការគណៈរដ្ឋមន្ត្រី